Titan Stone
Life Insurance

# បណ្ណសន្យារ៉ាប់រង

# ស្ដីពី

# មង្គលគ្រួសារ

## មាតិកា


| | |
|---|---|
| **ជំពូកទី I** | **បញ្ញត្តិទូទៅ** |
| ប្រការ១ ៖ | និយមន័យ |
| ប្រការ ២ ៖ | នីតិវិធីទិញធានារ៉ាប់រង |
| ប្រការ ៣ ៖ | កាតព្វកិច្ចក្នុងការផ្តល់ព័ត៌មានដោយម្ចាស់បណ្ណសន្យារ៉ាប់រង |
| ប្រការ៤ ៖ | ការធានារ៉ាប់រងបណ្តោះអាសន្ន |
| ប្រការ៥ ៖ | រយៈពេលសាកល្បង |
| ប្រការ៦ ៖ | កាលបរិច្ឆេទចាប់ផ្តើមទំនួលខុសត្រូវធានារ៉ាប់រង |
| **ជំពូកទី II** | **ការបង់បុព្វលាភធានារ៉ាប់រង** |
| ប្រការ៧ ៖ | កាតព្វកិច្ចបង់បុព្វលាភធានារ៉ាប់រង |
| ប្រការ៨ ៖ | រយៈពេលអនុគ្រោះបន្ថែម |
| **ជំពូកទី III** | **ការកែប្រែ និងការបន្តសុពលភាពឡើងវិញ** |
| ប្រការ៩ ៖ | ការកែប្រែបណ្ណសន្យារ៉ាប់រង |
| ប្រការ១០ ៖ | ការប្រកាសមិនត្រឹមត្រូវអំពីអាយុ និងភេទរបស់អ្នកត្រូវបានធានារ៉ាប់រង |
| ប្រការ១១ ៖ | ការបោះបង់បណ្ណសន្យារ៉ាប់រង |
| ប្រការ១២ ៖ | ការបន្តសុពលភាពឡើងវិញ |
| **ជំពូកទីIV** | **អត្ថប្រយោជន៍ធានារ៉ាប់រង** |
| ប្រការ១៣ ៖ | អត្ថប្រយោជន៍មរណភាព ឬ ពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍ |
| ប្រការ១៤ ៖ | ការបញ្ចប់បណ្ណសន្យារ៉ាប់រងដោយម្ចាស់បណ្ណសន្យារ៉ាប់រង |
| ប្រការ១៥៖ | ករណីដែលមិនធានា |
| **ជំពូកទី V** | **ដំណោះស្រាយលើការទាមទារសំណង** |
| ប្រការ១៦ ៖ | អ្នកទទួលបានអត្ថប្រយោជន៍ធានារ៉ាប់រង |
| ប្រការ១៧ ៖ | ការជូនដំណឹង និងការផ្តល់ភស្តុតាងនៃការទាមទារសំណង |
| ប្រការ១៨ ៖ | រយៈពេលកំណត់សម្រាប់ការស្នើសុំទូទាត់អត្ថប្រយោជន៍ធានារ៉ាប់រង |
| **ជំពូកទី VI** | **បញ្ញត្តិផ្សេងៗ** |
| ប្រការ១៩ ៖ | ការបញ្ចប់បបណ្ណសន្យារ៉ាប់រង |
| ប្រការ២០ ៖ | ការរក្សាការសម្ងាត់ព័ត៌មាន |
| ប្រការ២១ ៖ | ការផ្សះផ្សាវិវាទ |
| ប្រការ២២ ៖ | ច្បាប់គ្រប់គ្រង |

# ជំពូកទី I បញ្ញត្តិទូទៅ

## ប្រការ១ ៖ និយមន័យ

វាក្យសព្ទនិងឃ្លាប្រយោគដែលប្រើប្រាស់នៅក្នុងបណ្ណសន្យារ៉ាប់រងនេះត្រូវបានយល់និងបកស្រាយដូចខាងក្រោម៖

១.១ **បណ្ណសន្យារ៉ាប់រង** សំដៅដល់ឯកសារចងភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ដែលចេញដោយក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ អ៊ីនសួរ៉េន ម.ក ដោយមានកំណត់ខ្លឹមសារសំខាន់ៗ និងចែងអំពីលក្ខខណ្ឌលម្អិតដែលបានព្រមព្រៀងរវាងក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ អ៊ីនសួរ៉េន ម.ក និង អ្នកត្រូវបានធានារ៉ាប់រងនៅក្នុងកិច្ចសន្យាធានារ៉ាប់រង។ បណ្ណសន្យារ៉ាប់រង ត្រូវភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រធានារ៉ាប់រង ឬ ឯកសារពាក់ព័ន្ធផ្សេងៗទៀត។

១.២ **ទីតាន ស្តូន ឡាយហ្វ៍** សំដៅដល់ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ អ៊ិនសួរេន ម.ក។

១.៣ **ម្ចាស់បណ្ណសន្យារ៉ាប់រង** សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានសិទ្ធិស្របច្បាប់លើបណ្ណសន្យារ៉ាប់រង។

១.៤ **អ្នកត្រូវបានធានារ៉ាប់រង** សំដៅដល់រូបវន្តបុគ្គល ដែលទិញបណ្ណសន្យារ៉ាប់រង ក្នុងករណីមួយចំនួនអាចជាម្ចាស់បណ្ណសន្យារ៉ាប់រងផង និងអាចជាអ្នកត្រូវបានធានារ៉ាប់រងផង។

១.៥ **វិញ្ញាបនបត្រធានារ៉ាប់រង** សំដៅដល់ឯកសារដែលចេញដោយក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ ដើម្បីបញ្ជាក់ថាអ្នកត្រូវបានធានារ៉ាប់រងបានទិញការធានារ៉ាប់រង ពីក្រុមហ៊ុនធានារ៉ាប់រងខាងដើម។

១.៦ **អ្នកទទួលផល** សំដៅដល់តតិយជននៃកិច្ចសន្យា ដែលត្រូវបានកំណត់ថាមានសិទ្ធិស្របច្បាប់ក្នុងការទទួលផលប្រយោជន៍ពីកិច្ចសន្យាទាំងឡាយណាដែលទាក់ទងនឹងការធានារ៉ាប់រងលើអាយុជីវិតតែប៉ុណ្ណោះ។

១.៧ **អាយុធានារ៉ាប់រង** អាយុដែលត្រូវបានចាប់ផ្តើមធានារ៉ាប់រង សំដៅទៅលើអាយុរបស់អ្នកត្រូវបានធានារ៉ាប់រង នៅថ្ងៃកំណើតមុនកាលបរិច្ឆេទមានសុពលភាពនៃបណ្ណសន្យា-រ៉ាប់រង ហើយជាអាយុដែលត្រូវបានយកមកប្រើប្រាស់ជាមូលដ្ឋានក្នុងការគណនាបុព្វលាភធានារ៉ាប់រង។

១.៨ **ពាក្យស្នើសុំធានារ៉ាប់រង** រាប់បញ្ចូលទាំងទម្រង់បែបបទពាក្យស្នើសុំធានារ៉ាប់រងអាយុជីវិត សេចក្តីថ្លែង និងព័ត៌មានលាយលក្ខណ៍អក្សរផ្សេងទៀត ដែលបានចុះហត្ថលេខា និងបានដាក់ជូនក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ ដោយផ្ទាល់ ឬ ជំនួសឲ្យម្ចាស់បណ្ណសន្យារ៉ាប់រង ពាក់ព័ន្ធនឹងការស្នើសុំបណ្ណសន្យារ៉ាប់រងនេះ។

១.៩ **កាលបរិច្ឆេទមានសុពលភាពនៃបណ្ណសន្យារ៉ាប់រង** សំដៅដល់កាលបរិច្ឆេទបង្ហាញនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងដែលក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ បានទទួលស្គាល់ការទទួលបានបុព្វលាភធានារ៉ាប់រងដំបូងគ្រប់ចំនួន និង ពាក្យស្នើសុំធានារ៉ាប់រងពេញលេញពីម្ចាស់បណ្ណសន្យារ៉ាប់រង។

១.១០ **កាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង** សំដៅដល់កាលបរិច្ឆេទដែលក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ បានចេញវិញ្ញាបនបត្រធានារ៉ាប់រងដល់ម្ចាស់បណ្ណសន្យារ៉ាប់រង និងដែលបានបង្ហាញនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។

១.១១ **កាលបរិច្ឆេទខួបបណ្ណសន្យារ៉ាប់រង** សំដៅដល់កាលបរិច្ឆេទនៅក្នុងឆ្នាំប្រតិទិននីមួយៗដែលត្រូវគ្នានឹងកាលបរិច្ឆេទមានសុពលភាពនៃបណ្ណសន្យារ៉ាប់រង។

១.១២ **កាលបរិច្ឆេទផុតកំណត់បណ្ណសន្យារ៉ាប់រង** សំដៅដល់កាលបរិច្ឆេទចុងក្រោយនៃរយៈពេលធានារ៉ាប់រង ដូចដែលបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង ប្រសិនបើបណ្ណ-សន្យារ៉ាប់រងនៅតែមានសុពលភាព។

១.១៣ **បុព្វលាភធានារ៉ាប់រង** សំដៅដល់ចំនួនទឹកប្រាក់ដែលម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវបង់ទៅឲ្យក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ តាមការកំណត់របស់ក្រុមហ៊ុនទីតាន ស្តូន ឡាយ-ហ្វ៍ នៅក្នុងបណ្ណសន្យារ៉ាប់រង។

១.១៤ **កាតព្វកិច្ចបង់បុព្វលាភធានារ៉ាប់រង** ម្ចាស់បណ្ណសន្យារ៉ាប់រង ត្រូវទទួលខុសត្រូវបង់បុព្វលាភធានារ៉ាប់រងឲ្យបានគ្រប់ និងទាន់ពេលវេលា តាមចំនួន និងកាលបរិច្ឆេទកំណត់ត្រូវបង់បុព្វលាភធានារ៉ាប់រង ទោះបីជាម្ចាស់បណ្ណសន្យា រ៉ាប់រងមិនបានទទួលការជូនដំណឹងរំលឹកអំពីកាលបរិច្ឆេទកំណត់ត្រូវបង់បុព្វលាភធានារ៉ាប់រងក៏ដោយ។

១.១៥ **អត្ថប្រយោជន៍មូលដ្ឋាន** ដែលបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងសំដៅដល់អត្ថប្រយោជន៍នៃផលិតផលចម្បងក្នុងបណ្ណសន្យារ៉ាប់រងនេះ។

១.១៦ **ទឹកប្រាក់ត្រូវបានធានារ៉ាប់រង** សំដៅដល់ចំនួនទឹកប្រាក់នៃការធានារ៉ាប់រង ដែលបានផ្តល់ជូននៅក្នុងបណ្ណសន្យារ៉ាប់រងនេះ ពាក់ព័ន្ធនឹងអត្ថប្រយោជន៍មូលដ្ឋាន ដូចដែលបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។

១.១៧ **បុព្វលាភធានារ៉ាប់រងជាដំណាក់កាល** សំដៅដល់ចំនួនទឹកប្រាក់ដែលម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវបង់ជូនក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ នៅកាលបរិច្ឆេទកំណត់ត្រូវបង់បុព្វ-លាភធានារ៉ាប់រងស្របនឹងអត្ថប្រយោជន៍មូលដ្ឋាន ដូចដែលបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។

១.១៨ **តម្លៃសាច់ប្រាក់សុទ្ធនៃបណ្ណសន្យារ៉ាប់រង** សំដៅដល់ចំនួនទឹកប្រាក់សរុបដែលត្រូវទូទាត់ (ប្រសិនបើមាន) នៅពេលបញ្ឈប់បណ្ណសន្យារ៉ាប់រង (ដោយសារតែមូលហេតុក្រៅពីហេតុការណ៍ធានារ៉ាប់រង) ដែលរួមមាន៖

ក. តម្លៃបោះបង់បណ្ណសន្យារ៉ាប់រង(ដក)

ខ. បំណុលនានាដែលជំពាក់ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ (ប្រសិនបើមាន)។

១.១៩ **តម្លៃបោះបង់បណ្ណសន្យារ៉ាប់រង** សំដៅដល់ចំនួនទឹកប្រាក់ត្រូវទូទាត់នៅពេលបញ្ឈប់បណ្ណសន្យារ៉ាប់រង តាមសំណើរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ដរាបណាបណ្ណសន្យារ៉ាប់រងនៅតែមានសុពលភាពនាពេលស្នើសុំនោះ។ តម្លៃបោះបង់បណ្ណសន្យារ៉ាប់រងត្រូវបានកំណត់ក្នុងសំណើសុំការធានារ៉ាប់រង និងត្រូវបានភ្ជាប់មកជាមួយបណ្ណសន្យារ៉ាប់រង។

១.២០ **ហេតុការណ៍ធានារ៉ាប់រង** សំដៅដល់ហេតុការណ៍មួយ ឬច្រើន ជាកម្មវត្ថុដូចបានកំណត់នៅក្នុងបណ្ណសន្យារ៉ាប់រងនេះ ដែលក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ នឹងទូទាត់អត្ថប្រយោជន៍ធានា-រ៉ាប់រង ប្រសិនបើហេតុការណ៍នោះកើតឡើងចំពោះអ្នកត្រូវបានធានារ៉ាប់រង ដោយស្របតាម ខ និងលក្ខខណ្ឌនៃបណ្ណសន្យារ៉ាប់រងនេះ។

១.២១ **គ្រោះថ្នាក់ចៃដន្យ** សំដៅដល់ហេតុការណ៍សត្យានុម័តមួយ ឬច្រើនបន្តបន្ទាប់គ្នា ដែលកើតឡើងដោយសារវត្ថុ ឬឥទ្ធិពលខាងក្រៅដែលបណ្តាលឲ្យអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬរងរបួស។ ហេតុការណ៍ដែលបណ្តាលឲ្យទទួលមរណភាព ឬរបួសរូបរាងកាយនោះ ត្រូវតែមិនមែនដោយសារមូលហេតុពីជំងឺ ឬរោគ រួមទាំងការឆ្លងបាក់-តេរី ឬមេរោគ ទោះបីដោយផ្នែកឬទាំងស្រុងក៏ដោយ។ ហេតុការណ៍ទាំងនេះ អាចត្រូវបានកំណត់ថាជា "គ្រោះថ្នាក់ចៃដន្យ" លុះត្រាតែបំពេញលក្ខខណ្ឌតម្រូវដូចខាងក្រោម៖

ក. មិនបានដឹងមុន និងមិនមែនជាចេតនារបស់អ្នកត្រូវបានធានារ៉ាប់រង

ខ. ជាមូលហេតុតែមួយគត់ និងដោយផ្ទាល់ដែលបណ្តាលឲ្យអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាពឬរងរបួស។

១.២២ ***សកម្មភាពល្មើសច្បាប់*** សំដៅដល់ទង្វើដោយចេតនា ឬដោយគ្រោងទុកជាមុនរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ឬ អ្នកត្រូវបានធានារ៉ាប់រង ឬ អ្នកទទួលផល ដូចដែលមានចែងនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

១.២៣ ***ពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍*** សំដៅដល់អ្នកត្រូវបានធានារ៉ាប់រង ទទួលរងការបាត់បង់ទាំងស្រុង ឬ ពិការជាអចិន្ត្រៃយ៍ និងមិនអាចជាសះស្បើយជារៀងហូតនៃៈ

- ដៃទាំងពីរ ឬ
- ជើងទាំងពីរ ឬ
- ដៃម្ខាង និងជើងម្ខាង ឬ
- ភ្នែកទាំងពីរ ឬ
- ភ្នែកម្ខាង និងដៃម្ខាង ឬ
- ភ្នែកម្ខាង និងជើងម្ខាង

តាមនិយមន័យនេះ ការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយជារៀងហូតនៃៈ

- ភ្នែក សំដៅដល់ការបាត់បង់គ្រាប់ភ្នែក ឬ ការបាត់បង់សមត្ថភាពនៃការមើលឃើញ(ខ្វាក់ភ្នែក)
- ដៃ សំដៅដល់ការដាច់ឬពិការជាអចិន្ត្រៃយ៍ចាប់ពី កដៃឡើងលើ និង
- ជើង សំដៅដល់ការដាច់ឬពិការជាអចិន្ត្រៃយ៍ចាប់ពី កជើងឡើងលើ។

១.២៤ **សំណងធានារ៉ាប់រង** សំដៅដល់សំណងជាប្រាក់ ឬជាវត្ថុ ឬសំណងរួមជាប្រាក់និងជាវត្ថុដែលត្រូវសងដោយក្រុមហ៊ុន ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍

១.២៥ **អ្នកស្នើសុំធានារ៉ាប់រង** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលនឹងក្លាយជាអ្នកត្រូវបានធានារ៉ាប់រងពេលអនាគត ដែលបំពេញនិងចុះហត្ថលេខាលើទម្រង់បែបបទជាលាយលក្ខណ៍អក្សររបស់ក្រុមហ៊ុន ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ អំពីស្ថានភាពផ្ទាល់របស់បុគ្គលនោះ។

១.២៦ **ផលិតផលធានារ៉ាប់រង *"មង្គលគ្រួសារ"*** សំដៅដល់ផលិតផលធានារ៉ាប់រងដែលផ្តល់ការធានាលើកម្ចីឥណទានមានកាលកំណត់សម្រាប់ទឹកប្រាក់ត្រូវធានាប្រភេទថយចុះ និងទឹកប្រាក់ត្រូវធានាប្រភេទថេរ ក្នុងករណីមរណភាព ឬពិការភាពជាអចិន្ត្រៃយ៍របស់អ្នកត្រូវបានធានារ៉ាប់រង។ ប្រសិនបើមានគ្រោះអកុសលណាមួយកើតឡើង នោះប្រាក់កម្ចីដែលនៅសល់របស់អ្នកត្រូវបានធានារ៉ាប់រង ឬអ្នកខ្ចី នឹងត្រូវបានទូទាត់ដោយបណ្ណសន្យារ៉ាប់រង។

## ប្រការ ២ ៖ នីតិវិធីទិញធានារ៉ាប់រង

២.១ នៅពេលដាក់ពាក្យស្នើសុំធានារ៉ាប់រង ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវតែបំពេញទម្រង់បែបបទពាក្យស្នើសុំធានារ៉ាប់រងឲ្យបានពេញលេញ និងដោយស្មោះត្រង់ ចុះហត្ថលេខាផ្ទាល់ខ្លួន ភ្ជាប់ឯកសារបញ្ជាក់អត្តសញ្ញាណតាមការតម្រូវ និងត្រូវបង់បុព្វលាភធានារ៉ាប់រងជាលើកដំបូង។

២.២ ដើម្បីឲ្យឯកសារពាក្យស្នើសុំធានារ៉ាប់រងអាចទទួលយកបាន ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវតែមានទំនាក់ទំនងដែលអាចធានាបាន (ផលប្រយោជន៍ធានារ៉ាប់រង) ជាមួយនឹងអ្នកត្រូវបានធានារ៉ាប់រង។ ដោយយោងតាម ខ និងលក្ខខណ្ឌនៃបណ្ណសន្យារ៉ាប់រងនេះ ម្ចាស់បណ្ណសន្យារ៉ាប់រងមានទំនាក់ទំនងដែលអាចធានាបានជាមួយអ្នកត្រូវបានធានារ៉ាប់រងគឺៈ

ក. ខ្លួនឯង ឬ

ខ. ប្រពន្ធ ប្តី កូន ឪពុក ម្តាយដែលទទួលស្គាល់ស្របច្បាប់ ឬ

គ. បងប្អូនបង្កើត អ្នកថែទាំ ឬ អាណាព្យាបាលស្របច្បាប់ ឬ

ឃ. ចៅ ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងគឺជាជីតា ឬ ជីដូនបង្កើត ខាងម្តាយ ឬ ខាងឪពុក ឬ

ង. រូបវន្តបុគ្គល ឬនីតិបុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងអាចធានាបាន (ផលប្រយោជន៍ធានារ៉ាប់រង) ដូចដែលបានកំណត់នៅក្នុងច្បាប់ស្តីពីការធានារ៉ាប់រងនៃព្រះរាជាណាចក្រកម្ពុជា។

២.៣ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រង មានអាយុក្រោម១៨ (ដប់ប្រាំបី) ឆ្នាំ ហើយម្ចាស់បណ្ណសន្យារ៉ាប់រងមិនមែនជាឪពុក ឬម្តាយ ឬ អាណាព្យាបាលរបស់អ្នកត្រូវបានធានារ៉ាប់រង នោះត្រូវមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរដោយឪពុក ឬ ម្តាយ ឬ អាណាព្យាបាលរបស់អ្នកត្រូវបានធានារ៉ាប់រងស្តីពីការទិញធានារ៉ាប់រងប្រគល់ជូន ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍។

២.៤ ជាការយល់ព្រមផ្តល់ការធានា ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ នឹងចេញបណ្ណសន្យារ៉ាប់រងដែលមានសុពលភាពគិតចាប់ពីកាលបរិច្ឆេទដូចបានបង្ហាញនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។ ប្រសិនបើពាក្យស្នើសុំធានារ៉ាប់រងត្រូវបានបដិសេធ នោះក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ នឹងប្រគល់បុព្វលាភធានារ៉ាប់រងដែលបានបង់រួចជូនទៅម្ចាស់បណ្ណសន្យារ៉ាប់រងវិញ។

## ប្រការ ៣ ៖ ភាតព្វកិច្ចក្នុងការផ្តល់ព័ត៌មានដោយម្ចាស់បណ្ណសន្យារ៉ាប់រង

ក. ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវតែផ្តល់ព័ត៌មានពេញលេញ និងស្មោះត្រង់នៅក្នុងទម្រង់បែបបទពាក្យស្នើសុំធានារ៉ាប់រង សេចក្តីថ្លែងអំពីសុខភាព និងសំណើសុំកែប្រែ ឬ បំពេញបន្ថែមព័ត៌មានដែលតម្រូវដោយ ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ ដើម្បីធ្វើជាមូលដ្ឋាននៃទំនាក់ទំនងកិច្ចសន្យាធានារ៉ាប់រង ឬការបន្តសុពលភាពរវាងភាគីទាំងពីរ។ តាមឆន្ទានុសិទ្ធិរបស់ខ្លួនក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ អាចស្នើសុំអ្នកត្រូវបានធានារ៉ាប់រង ឲ្យទទួលការពិនិត្យសុខភាព ប៉ុន្តែការពិនិត្យសុខភាពនោះ (ប្រសិនបើមាន) នឹងមិនអាចជំនួសឲ្យកាតព្វកិច្ចរបស់ម្ចាស់បណ្ណសន្យារ៉ាប់រងក្នុងការផ្តល់នូវព័ត៌មានពេញលេញ និងស្មោះត្រង់តាមការតម្រូវនៅក្នុងប្រការនេះឡើយ។

ខ. ក្នុងករណីដែលម្ចាស់បណ្ណសន្យារ៉ាប់រងបំពាន ប្រការ៣ ចំណុច ក ខាងលើហើយប្រសិនបើមានការក្លែងបន្លំ ការមិនផ្តល់ព័ត៌មាន ការបកស្រាយខុស ឬ ការថ្លែងមិនត្រឹមត្រូវខុសពីការពិត នោះក្រុមហ៊ុន ទីតាន ស្តូន ឡាយហ្វ៍ មានសិទ្ធិលុបចោលបណ្ណសន្យារ៉ាប់រងជាឯកតោភាគី និងប្រមូលបំណុលដែលមាន។ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ នឹង (១)ទូទាត់ ត្រឡប់វិញនូវបុព្វលាភធានារ៉ាប់រងដែលបានបង់រួច (២)ដកមកវិញនូវអត្ថប្រយោជន៍នានាដែលក្រុមហ៊ុនទីតាន ស្តូន ឡាយ

ហ្វ៍បានទូទាត់ជូនទាំងអស់ (៣)ដកមកវិញនូវថ្លៃចំណាយលើការពិនិត្យសុខភាព (ប្រសិនបើមាន) (៤)ដកមកវិញនូវចំនួនទឹកប្រាក់ដែលនៅជំពាក់ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ (ប្រសិនបើមាន)។

### ប្រការ៤ ៖ ការធានារ៉ាប់រងបណ្តោះអាសន្ន

ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ នឹងទូទាត់ទឹកប្រាក់ចំនួន ១០០% (មួយរយភាគរយ) នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រង ដែលបានស្នើដោយម្ចាស់បណ្ណសន្យារ៉ាប់រង ក្នុងករណីមរណភាពដោយសារគ្រោះថ្នាក់ចៃដន្យរបស់អ្នកត្រូវបានធានារ៉ាប់រង ក្នុងអំឡុងពេលធានារ៉ាប់រងបណ្តោះអាសន្ន។ ករណីអត្ថប្រយោជន៍នេះត្រូវបានទូទាត់រួច នោះបុព្វលាភធានារ៉ាប់រងដំបូងនឹងមិនត្រូវបានប្រគល់ជូនម្ចាស់បណ្ណសន្យារ៉ាប់រងវិញឡើយ។

រយៈពេលធានារ៉ាប់រងបណ្តោះអាសន្នយូរបំផុត ៣០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទមានសុពលភាពនៃបណ្ណសន្យារ៉ាប់រង។

ប្រសិនបើក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ បានចេញវិញ្ញាបនបត្រធានារ៉ាប់រង នោះរយៈពេលធានារ៉ាប់រងបណ្តោះអាសន្ន នឹងក្លាយជាមោឃៈចាប់ពីកាលបរិច្ឆេទមានសុពលភាពនៃបណ្ណសន្យារ៉ាប់រង ហើយអត្ថប្រយោជន៍ធានារ៉ាប់រងដូចដែលបានចែងក្នុង ជំពូកទី៤ (បួន) នឹងចាប់ផ្តើមកាលបរិច្ឆេទមានសុពលភាពនៃបណ្ណសន្យារ៉ាប់រង។

ប្រសិនបើក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ សម្រេចពន្យាដំណើរការ ឬបដិសេធពាក្យស្នើសុំធានារ៉ាប់រងនោះ រយៈពេលធានារ៉ាប់រងបណ្តោះអាសន្ននឹងផុតកំណត់ភ្លាមៗ។

ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ នឹងមិនទូទាត់អត្ថប្រយោជន៍ធានារ៉ាប់រងបណ្តោះអាសន្នដូចបានបញ្ជាក់ខាងលើឡើយ ប្រសិនបើមរណភាពរបស់អ្នកត្រូវបានធានារ៉ាប់រងកើតឡើងដោយសារមូលហេតុណាមួយទោះដោយផ្ទាល់ ឬដោយប្រយោល ដូចខាងក្រោម៖

ក. អំពើអត្តឃាត ដោយមិនគិតពីស្ថានភាពផ្លូវចិត្តរបស់អ្នកត្រូវបានធានារ៉ាប់រងឡើយ ឬ

ខ. ការប្រើប្រាស់គ្រឿងញៀន ថ្នាំរំញោចឬគ្រឿងស្រវឹងដែលល្មើសទៅនឹងច្បាប់នៃព្រះរាជាណាចក្រ កម្ពុជា ឬ

គ. បទល្មើសព្រហ្មទណ្ឌដែលប្រព្រឹត្តដោយម្ចាស់បណ្ណសន្យារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផលឬ

ឃ. ហេតុការណ៍គ្រោះថ្នាក់ចៃដន្យ ដែលបណ្តាលឲ្យអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាពបានកើតឡើងមុនពេលចាប់ផ្តើមនៃការធានារ៉ាប់រងបណ្តោះអាសន្ន។

ក្នុងករណីនេះ ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ នឹងបង្វិលបុព្វលាភធានារ៉ាប់រងទាំងអស់ដែលបានបង់រួចជូនទៅម្ចាស់បណ្ណសន្យារ៉ាប់រងវិញ។

### ប្រការ៥ ៖ រយៈពេលសាកល្បង

ក្នុងរយៈពេល ២១ (ម្ភៃមួយថ្ងៃ) ចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតអះអាងនៃការទទួលបាននូវបណ្ណសន្យារ៉ាប់រងពីក្រុមហ៊ុនទីតានស្តូន ឡាយហ្វ៍ ម្ចាស់បណ្ណសន្យារ៉ាប់រងអាចស្នើសុំកែប្រែ កែសម្រួល ឬលុបចោលបណ្ណសន្យារ៉ាប់រងបាន ប្រសិនបើគ្មានហេតុការណ៍ធានារ៉ាប់រង ឬការទាមទារសំណងធានារ៉ាប់រងកើតឡើងនៅរយៈពេលនេះ។ ក្នុងករណីម្ចាស់បណ្ណសន្យារ៉ាប់រងប្រគល់ត្រឡប់មកវិញនូវបណ្ណសន្យារ៉ាប់រង ព្រមជាមួយ ការចង្អុលបង្ហាញជាលាយលក្ខណ៍អក្សរ ដើម្បីលុបចោលបណ្ណសន្យារ៉ាប់រងក្នុងរយៈពេលសាកល្បងនេះ នោះក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ នឹងប្រគល់ត្រឡប់វិញនូវបុព្វលាភធានារ៉ាប់រងនានា ដែលបានបង់រួច ដោយគ្មានការប្រាក់ បន្ទាប់ពីកាត់កងចំណាយពិនិត្យសុខភាព និងចំណាយផ្សេងៗដែលពាក់ព័ន្ធ (ប្រសិនបើមាន)។

### ប្រការ៦ ៖ កាលបរិច្ឆេទចាប់ផ្តើមទំនួលខុសត្រូវធានារ៉ាប់រង

ការទទួលខុសត្រូវធានារ៉ាប់រងរបស់ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ នឹងត្រូវកើតមានឡើងពីកាលបរិច្ឆេទមាន សុពលភាពនៃបណ្ណសន្យារ៉ាប់រង ដូចដែលបានបង្ហាញនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង។

## ជំពូកទី II ការបង់បុព្វលាភធានារ៉ាប់រង

### ប្រការ៧ ៖ កាតព្វកិច្ចបង់បុព្វលាភធានារ៉ាប់រង

ម្ចាស់បណ្ណសន្យារ៉ាប់រង ត្រូវទទួលខុសត្រូវបង់បុព្វលាភធានារ៉ាប់រងឲ្យបានគ្រប់ និងទាន់ពេលវេលាតាមចំនួន និងកាលបរិច្ឆេទកំណត់ត្រូវបង់បុព្វលាភធានារ៉ាប់រងដូចដែលបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង ឬ ឯកសារភ្ជាប់ផ្សេងទៀត (ប្រសិនបើមាន) ទោះបីជាម្ចាស់បណ្ណសន្យារ៉ាប់រងមិនបានទទួលការជូនដំណឹងរំលឹកអំពីកាលបរិច្ឆេទកំណត់ត្រូវបង់បុព្វលាភធានារ៉ាប់រងក៏ដោយ។

### ប្រការ៨ ៖ រយៈពេលអនុគ្រោះបន្ថែម

៨.១ រយៈពេលអនុគ្រោះបន្ថែមដែលមានចំនួន៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទកំណត់ត្រូវបង់បុព្វលាភធានារ៉ាប់រងត្រូវបានអនុញ្ញាតសម្រាប់ការបង់បុព្វលាភធានារ៉ាប់រងនីមួយៗ។ ក្នុងរយៈពេលអនុគ្រោះបន្ថែមនេះ បណ្ណសន្យារ៉ាប់រងនៅតែមានសុពលភាពដដែល។ ក្នុងករណីមានការទាមទារអត្ថប្រយោជន៍ធានារ៉ាប់រង ក្នុងអំឡុងនៃរយៈពេលអនុគ្រោះបន្ថែម ដែលក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍បានរក្សាសុពលភាពបណ្ណសន្យារ៉ាប់រងនេះ ម្ចាស់បណ្ណសន្យារ៉ាប់រងមានការទទួលខុសត្រូវចំពោះក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ ក្នុងការសងបុព្វលាភធានារ៉ាប់រងដែលមិនទាន់បានបង់ទាំងអស់។

៨.២ ប្រសិនបើបុព្វលាភធានារ៉ាប់រង មិនត្រូវបានបង់នៅចុងបញ្ចប់នៃរយៈពេលអនុគ្រោះបន្ថែមទេ នោះបណ្ណសន្យារ៉ាប់រងនឹងត្រូវបានចាត់ទុកជាមោឃៈ គិតចាប់ពីកាលបរិច្ឆេទកំណត់ត្រូវបង់បុព្វលាភធានារ៉ាប់រងចុងក្រោយ ហើយម្ចាស់បណ្ណសន្យារ៉ាប់រង នឹងមិនអាចស្នើសុំទាមទារបុព្វលាភធានារ៉ាប់រងដែលបានបង់រួចវិញឡើយ។

## ជំពូកទី III ការកែប្រែ និងការបន្តសុពលភាពឡើងវិញ

### ប្រការ៩ ៖ ការកែប្រែបណ្ណសន្យារ៉ាប់រង

៩.១ **ការផ្ទេរសិទ្ធិ**

៩.១.១ ក្នុងអំឡុងពេលបណ្ណសន្យារ៉ាប់រងកំពុងមានសុពលភាព ម្ចាស់បណ្ណសន្យារ៉ាប់រងអាចធ្វើការស្នើសុំផ្ទេរ បណ្ណសន្យារ៉ាប់រងនេះបាន តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុន ទីតាន ស្តូន ឡាយហ្វ៍។ អ្នកទទួលសិទ្ធិស្របច្បាប់ត្រូវបំពេញតាមលក្ខណៈវិនិច្ឆ័យពេញសិទ្ធិទាំងអស់ សម្រាប់ម្ចាស់បណ្ណសន្យារ៉ាប់រង និងត្រូវមានការប្តេជ្ញាចិត្ត អនុវត្តតាម ខ និងលក្ខខណ្ឌដែលមានចែងនៅក្រោមបណ្ណសន្យារ៉ាប់រងនេះ។ អ្នកត្រូវបានធានារ៉ាប់រងនឹងនៅតែជាអ្នកត្រូវបានធានារ៉ាប់រង ដែល

មានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រ ធានារ៉ាប់រងដដែល។ ការផ្ទេរសិទ្ធិនេះត្រូវតែទទួលបានការយល់ព្រមពីអ្នកត្រូវបានធានារ៉ាប់រង ឬឪពុក ឬម្ដាយ ឬអាណាព្យាបាល ស្របច្បាប់របស់អ្នកត្រូវបានធានារ៉ាប់រង ប្រសិនបើអ្នកត្រូវបានធានានារ៉ាប់រង មានអាយុតិចជាង ១៨ (ដប់ប្រាំបី) ឆ្នាំ។ ការផ្ទេរសិទ្ធិនេះមានសុពលភាពគិតចាប់ពីកាលបរិច្ឆេទ ដែលបានបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការអនុម័តយល់ព្រមលើការផ្ទេរសិទ្ធិដោយក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ តែប៉ុណ្ណោះ។

៩.១.២ **បន្ទាប់ពីការផ្ទេរសិទ្ធិ ចូលជាធរមាន៖**

ក. អត្ថប្រយោជន៍ធានារ៉ាប់រង និងការទទួលខុសត្រូវទាំងអស់របស់ម្ចាស់បណ្ណសន្យារ៉ាប់រងចាស់នឹងត្រូវបានលុបចោល។

ខ. អ្នកទទួលសិទ្ធិស្របច្បាប់នឹងក្លាយជាម្ចាស់បណ្ណសន្យារ៉ាប់រងថ្មីព្រមទាំងមានសិទ្ធិ និងកាតព្វកិច្ចទាំងអស់ដែលមានកំណត់ក្នុងបណ្ណសន្យារ៉ាប់រងនេះ។

គ. រាល់អ្នកទទួលផល ដែលត្រូវបានចាត់តាំងដោយម្ចាស់បណ្ណសន្យារ៉ាប់រងចាស់នឹងត្រូវលុបចោលដោយស្វ័យប្រវត្តិ។

ឃ. អ្នកត្រូវបានធានារ៉ាប់រងដែលបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងនឹងគ្មានការផ្លាស់ប្តូរឡើយ។

៩.១.៣ ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ នឹងមិនទទួលខុសត្រូវចំពោះបញ្ហាទាំងឡាយណាដែលកើតឡើងពីការផ្ទេរសិទ្ធិនេះឡើយ។

៩.២ **ការចាត់តាំង និងការផ្លាស់ប្តូរអ្នកទទួលផល**

៩.២.១ ម្ចាស់បណ្ណសន្យារ៉ាប់រងមានសិទ្ធិចាត់តាំងអ្នកទទួលផលម្នាក់ ឬច្រើននាក់ឲ្យទទួលអត្ថប្រយោជន៍ធានារ៉ាប់រងទាំងអស់ ឬដោយផ្នែក ស្របតាមបណ្ណសន្យារ៉ាប់រងនេះ។ ម្ចាស់បណ្ណសន្យារ៉ាប់រងអាចបញ្ជាក់អំពីចំណែក ដែលអ្នកទទួលផលម្នាក់ៗនឹងទទួលបាន។ ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងមិនបានបញ្ជាក់ពីចំណែកទេនោះ អ្នកទទួលផលទាំងអស់នឹងទទួលអត្ថប្រយោជន៍ក្នុងចំណែកស្មើៗគ្នា។

៩.២.២ ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងមិនបានចាត់តាំងអ្នកទទួលផលទេនោះ អត្ថប្រយោជន៍នឹងត្រូវបានទូទាត់ទៅឲ្យទាយាទស្របច្បាប់របស់អ្នកត្រូវបានធានារ៉ាប់រង។

៩.២.៣ ក្នុងអំឡុងពេលបណ្ណសន្យារ៉ាប់រងកំពុងមានសុពលភាព ម្ចាស់បណ្ណសន្យារ៉ាប់រងមានសិទ្ធិផ្លាស់ប្តូរអ្នកទទួលផល ឬចំណែករបស់អ្នកទទួលផលគ្រប់ពេល ប៉ុន្តែត្រូវមានការទទួលស្គាល់យល់ព្រមជាលាយ លក្ខណ៍អក្សរដោយក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ ទើបការផ្លាស់ប្តូរនោះអាចមានសុពលភាពបាន។

៩.២.៤ ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ នឹងមិនទទួលខុសត្រូវផ្លូវច្បាប់សម្រាប់ការចាត់តាំង ឬ ការផ្លាស់ប្តូរអ្នកទទួលផលឡើយ។

៩.៣ **ការផ្លាស់ប្តូរក្នុងករណីម្ចាស់បណ្ណសន្យារ៉ាប់រងទទួលមរណភាព**

៩.៣.១ ក្នុងអំឡុងពេលបណ្ណសន្យារ៉ាប់រងកំពុងមានសុពលភាព ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងទទួលមរណភាព ប៉ុន្តែអ្នកត្រូវបានធានារ៉ាប់រងនៅមានជីវិត នោះទាយាទស្របច្បាប់ម្នាក់ ឬច្រើននាក់ របស់ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវមានកាតព្វកិច្ចទាំងអស់ដែលមានកំណត់ក្នុងមបណ្ណសន្យារ៉ាប់រង ដោយស្របតាមច្បាប់ស្តីអំពីមរតកនៃព្រះរាជាណាចក្រកម្ពុជា។

៩.៣.២ ក្នុងករណីមានទាយាទច្រើនជាងម្នាក់ ពួកគេទាំងអស់ត្រូវតែព្រមព្រៀងគ្នាដើម្បីចាត់តាំង ឬ អនុញ្ញាតឲ្យទាយាទដែលបំពេញតាមលក្ខណៈវិនិច្ឆ័យពេញសិទ្ធិដើម្បីក្លាយជាម្ចាស់បណ្ណសន្យារ៉ាប់រងថ្មី។

៩.៣.៣ ប្រសិនបើទាយាទស្របច្បាប់ម្នាក់ ឬ ច្រើននាក់របស់ម្ចាស់បណ្ណសន្យារ៉ាប់រង មិនចង់បន្តបណ្ណសន្យារ៉ាប់រងពួកគេត្រូវតែជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ នៅក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលម្ចាស់បណ្ណសន្យារ៉ាប់រងទទួលមរណភាព។

៩.៣.៤ ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ នឹងមិនទទួលខុសត្រូវផ្លូវច្បាប់ចំពោះវិវាទណាមួយដែលកើតចេញពីការតែងតាំងម្ចាស់បណ្ណសន្យារ៉ាប់រងថ្មីដោយទាយាទខាងលើនោះឡើយ។

៩.៤ **ករណីដែលម្ចាស់បណ្ណសន្យារ៉ាប់រងជានីតិបុគ្គល**

ក្នុងករណីដែលម្ចាស់បណ្ណសន្យារ៉ាប់រងជាអង្គភាពត្រូវបានក្ស័យធន ឬ ត្រូវបានរំលាយ ឬ ត្រូវបានបញ្ចប់ក្នុងខណៈពេលដែលបណ្ណសន្យារ៉ាប់រងនៅមានសុពលភាព នោះបណ្ណសន្យារ៉ាប់រងនឹងត្រូវបញ្ឈប់ហើយក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ នឹងទូទាត់តម្លៃសាច់ប្រាក់សុទ្ធ (ប្រសិនបើមាន) ជូនដល់អ្នកទទួលបានអត្ថប្រយោជន៍ធានារ៉ាប់រង។

៩.៥ **ការផ្លាស់ប្តូរព័ត៌មានទំនាក់ទំនង**

ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រង និងឬ អ្នកត្រូវបានធានារ៉ាប់រង ផ្លាស់ប្តូរព័ត៌មានទំនាក់ទំនង ឬ ឈ្មោះ ឬលេខអត្តសញ្ញាណបណ្ណ នោះម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការផ្លាស់ប្តូរនោះដល់ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ នៅក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៃការផ្លាស់ប្តូរ។

## ប្រការ១០ ៖ ការប្រកាសមិនត្រឹមត្រូវអំពីអាយុ និងភេទរបស់អ្នកត្រូវបានធានារ៉ាប់រង

១០.១ ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវផ្តល់ព័ត៌មានអំពីថ្ងៃខែឆ្នាំកំណើត និងភេទពិតប្រាកដរបស់អ្នកត្រូវបានធានារ៉ាប់រង នៅក្នុងពាក្យស្នើសុំធានារ៉ាប់រង ពេលបំពេញពាក្យស្នើសុំបណ្ណសន្យារ៉ាប់រង។ ក្នុងករណីរកឃើញកំហុសបន្ទាប់ពីវិញ្ញាបនបត្រធានារ៉ាប់រងត្រូវបានចេញដោយក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ នោះតម្រូវឲ្យធ្វើការកែប្រែស្របតាមវិធានដូចខាងក្រោម៖

ក. ប្រសិនបើអាយុ និងឬ ភេទពិតប្រាកដរបស់អ្នកត្រូវបានធានារ៉ាប់រង ធ្វើឲ្យមានការបង់បុព្វលាភធានារ៉ាប់រងខ្ពស់ជាងចំនួនដែលបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង នោះទឹកប្រាក់ត្រូវបានធានារ៉ាប់រងត្រូវតែកាត់បន្ថយមកត្រឹមកម្រិតដែលអាចអនុវត្តបានចំពោះអាយុ និងឬភេទពិតប្រាកដនិងបុព្វលាភធានារ៉ាប់រងដែលបានបង់រួច។

ខ. ប្រសិនបើអាយុ និងឬភេទពិតប្រាកដរបស់អ្នកត្រូវបានធានារ៉ាប់រង ធ្វើឲ្យមានការបង់បុព្វលាភធានារ៉ាប់រងទាបជាងចំនួនដែលបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង នោះបុព្វលាភធានារ៉ាប់រងដែលត្រូវបង់នឹងត្រូវបានកាត់បន្ថយមកត្រឹមកម្រិតដែលអាចអនុវត្តបានចំពោះអាយុ និងឬ ភេទពិតប្រាកដ និងទឹកប្រាក់ត្រូវបានធានារ៉ាប់រងដែលបានជ្រើសរើសរួច។ ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ នឹងប្រគល់ត្រឡប់វិញជូនម្ចាស់បណ្ណសន្យារ៉ាប់រងនូវបុព្វលាភធានារ៉ាប់រង ដែលលើសចំនួនដោយគ្មានការប្រាក់។ អត្ថប្រយោជន៍នានាដែលស្ថិតនៅក្រោមបណ្ណសន្យារ៉ាប់រងនឹងនៅដដែលដោយគ្មានការកែប្រែឡើយ។

គ. ប្រសិនបើ អាយុពិតប្រាកដរបស់អ្នកត្រូវបានធានារ៉ាប់រង នៅកាលបរិច្ឆេទមានសុពលភាពនៃបណ្ណសន្យារ៉ាប់រងមិនស្ថិតនៅក្នុងអាយុធានារ៉ាប់រងសមស្របសម្រាប់ការចេញបណ្ណសន្យារ៉ាប់រងទេនោះ បណ្ណសន្យារ៉ាប់រង នឹងត្រូវចាត់ទុកជាមោឃៈ។ នៅក្នុងករណីនេះក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ នឹងប្រគល់ត្រឡប់វិញនូវបុព្វលាភធានារ៉ាប់រងទាំងអស់ដែលបានបង់រួចពាក់ព័ន្ធនឹងអត្ថប្រយោជន៍ផ្សេងៗដែលត្រូវបានមោឃភាពដោយ មិនមានការប្រាក់បន្ទាប់ពីបានដកថ្លៃចំណាយផ្សេងៗ (ប្រសិនបើមាន)។ ដូច្នេះរាល់កាតព្វកិច្ចទាំងអស់របស់ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ ដែលស្ថិតនៅក្រោមអត្ថប្រយោជន៍ធានារ៉ាប់រងដែលត្រូវបានលុបចោលនេះនឹងត្រូវបញ្ចប់។

### ប្រការ១១ ៖ ការបោះបង់បណ្ណសន្យារ៉ាប់រង

ម្ចាស់បណ្ណសន្យារ៉ាប់រង មានសិទ្ធិបោះបង់បណ្ណសន្យារ៉ាប់រងគ្រប់ពេលវេលា។ សំណើសុំបោះបង់បណ្ណសន្យារ៉ាប់រង អាចធ្វើឡើងដោយការប្រើប្រាស់ទម្រង់បែបបទស្នើសុំដែលផ្តល់ជូនដោយក្រុមហ៊ុនសម្រាប់ការទូទាត់អត្ថប្រយោជន៍ធានារ៉ាប់រង។ សំណើសុំបោះបង់បណ្ណសន្យារ៉ាប់រង មានសុពលភាពនៅពេលដែលម្ចាស់បណ្ណសន្យារ៉ាប់រងទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរ ដែលត្រូវបានអនុម័តដោយក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍។ នៅពេលដែលក្រុមហ៊ុន បានទូទាត់តម្លៃបោះបង់បណ្ណសន្យារ៉ាប់រងរួច នោះបណ្ណសន្យារ៉ាប់រងត្រូវបញ្ឈប់ ហើយគ្មានអត្ថប្រយោជន៍ធានារ៉ាប់រងក្រោមបណ្ណសន្យារ៉ាប់រងត្រូវអនុវត្តទៀតឡើយ។

### ប្រការ១២ ៖ ការបន្តសុពលភាពឡើងវិញ

១២.១ ប្រសិនបើបណ្ណសន្យារ៉ាប់រងនេះត្រូវបានលុបចោល ដោយសារតែការមិនបានបង់បុព្វលាភធានារ៉ាប់រងនោះម្ចាស់បណ្ណសន្យារ៉ាប់រងអាចស្នើសុំជាលាយលក្ខណ៍អក្សរមកកាន់ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ដើម្បីបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ លុះត្រាតែបំពេញតាមលក្ខខណ្ឌតម្រូវដូចខាងក្រោម៖

- ក. ម្ចាស់បណ្ណសន្យារ៉ាប់រង ត្រូវដាក់ឯកសារស្នើសុំបន្តសុពលភាពឡើងវិញជូនក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ នៅក្នុងរយៈពេល២(ពីរ)ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទអស់សុពលភាពចុងក្រោយ។
- ខ. ម្ចាស់បណ្ណសន្យារ៉ាប់រង ត្រូវបង់បុព្វលាភធានារ៉ាប់រងទាំងអស់ដែលនៅសល់បូករួមទាំងការប្រាក់ដែលអាចអនុវត្តបាន ជូនក្រុមហ៊ុន ទីតាន ស្តូន ឡាយហ្វ៍ ដោយស្របតាម ខ និងលក្ខខណ្ឌនៃបណ្ណសន្យារ៉ាប់រងនេះ។
- គ. ម្ចាស់បណ្ណសន្យារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រង នៅតែមានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការទទួលបានការធានារ៉ាប់រង ដូចដែលបានបញ្ជាក់ក្នុងបណ្ណសន្យារ៉ាប់រងនេះ។

១២.២ ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវតែផ្តល់ព័ត៌មានដោយពេញលេញ និងស្មោះត្រង់នៅក្នុងទម្រង់បែបបទស្នើសុំបន្តសុពលភាពឡើងវិញ សេចក្តីថ្លែងអំពីសុខភាព និងឯកសារផ្សេងទៀតដែលកំណត់ដោយក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍។ តាមឆន្ទានុសិទ្ធិរបស់ខ្លួន ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ អាចស្នើសុំឲ្យអ្នកត្រូវបានធានារ៉ាប់រង ទទួលការពិនិត្យសុខភាព។ ប៉ុន្តែការពិនិត្យសុខភាពនោះ (ប្រសិនបើមាន) នឹងមិនអាចជំនួសឲ្យកាតព្វកិច្ចរបស់ម្ចាស់បណ្ណសន្យារ៉ាប់រងក្នុងការផ្តល់ព័ត៌មានពេញលេញ និងស្មោះត្រង់តាមការតម្រូវនៅក្នុងប្រការនេះទេ។

១២.៣ ប្រសិនបើការបន្តសុពលភាពឡើងវិញត្រូវបានអនុម័តយល់ព្រម នោះកាលបរិច្ឆេទមានសុពលភាពនៃការបន្តសុពលភាពឡើងវិញត្រូវគិត ចាប់ពីកាលបរិច្ឆេទដូចបានបង្ហាញនៅក្នុងលិខិតជូនដំណឹងពីការបន្តសុពល ភាពឡើងវិញ ដែលត្រូវបានអនុម័តដោយក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ និងដរាបណាអ្នកត្រូវបានធានារ៉ាប់រង នៅមានជីវិតនាខណៈពេលនោះ។

## ជំពូកទីIV អត្ថប្រយោជន៍ធានារ៉ាប់រង

### ប្រការ១៣ ៖ អត្ថប្រយោជន៍មរណភាព ឬ ពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍

១៣.១ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រង ទទួលមរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍ នៅពេលដែលបណ្ណសន្យារ៉ាប់រងនៅតែមានសុពលភាព នោះក្រុមហ៊ុន ទីតាន ស្តូន ឡាយហ្វ៍ នឹងទូទាត់អត្ថប្រយោជន៍ធានារ៉ាប់រងដូចខាងក្រោម៖

- ក. ១០០% (មួយរយភាគរយ) នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រង នឹងត្រូវទូទាត់នៅពេលមរណភាព ។
- ខ. ១៣០% (មួយរយសាមសិបភាគរយ) នៃទឹកប្រាក់ត្រូវបានធានារ៉ាប់រង នឹងត្រូវទូទាត់នៅពេល ពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍។

១៣.២ **លក្ខខណ្ឌសម្រាប់ការទាមទារសំណង៖**

- ក. អ្នកទាមទារសំណងត្រូវផ្តល់ភស្តុតាងច្បាស់លាស់មកកាន់ក្រុមហ៊ុន ទីតាន ស្តូន ឡាយហ្វ៍ អំពីមរណភាពរបស់អ្នកត្រូវបានធានារ៉ាប់រង។
- ខ. ដើម្បីទទួលបានសិទ្ធិក្នុងការស្នើសុំទាមទារសំណង លើករណីពិការភាពទាំងស្រុង និង អចិន្ត្រៃយ៍អ្នកត្រូវបានធានារ៉ាប់រង ត្រូវតែទទួលបានការបញ្ជាក់អំពីពិការភាពទាំងស្រុង និងអចន្ត្រៃយ៍ដោយមន្ទីរពេទ្យដែលចុះបញ្ជីត្រឹមត្រូវតាមច្បាប់ចាប់ពីថ្នាក់ខេត្ត ឬរាជធានីឡើងទៅ និងត្រូវផ្តល់ភស្តុតាងច្បាស់លាស់មកកាន់ក្រុមហ៊ុន ទីតាន ស្តូន ឡាយហ្វ៍។
- គ. ក្នុងករណីខ្វិនជាអចិន្ត្រៃយ៍ លក្ខណៈពិការភាពទាំងស្រុងនិងអចិន្ត្រៃយ៍ ត្រូវតែទទួលបានការបញ្ជាក់ដោយមន្ទីរពេទ្យដែលចុះបញ្ជីត្រឹមត្រូវតាមច្បាប់ចាប់ពីថ្នាក់ខេត្ត ឬរាជធានីឡើងទៅ និងត្រូវផ្តល់ភស្តុតាងច្បាស់លាស់មកកាន់ក្រុមហ៊ុន ទីតាន ស្តូន ឡាយហ្វ៍។ ការបញ្ជាក់នេះត្រូវធ្វើឡើងមិនឲ្យឆាប់ជាង៦ (ប្រាំមួយ) ខែនិងមិនឲ្យយឺតជាង៩(ប្រាំបួន)ខែបន្ទាប់ពីកាលបរិច្ឆេទគ្រោះថ្នាក់កើតឡើងឬនៅកាលបរិច្ឆេទដែលលក្ខណៈខ្វិនត្រូវបានផ្ទៀងផ្ទាត់។
- ឃ. ក្នុងករណីបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយជារៀងរហូត ដូចមានចែងក្នុងចំណុច១.២៣ ការបញ្ជាក់អំពីលក្ខណៈពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍អាចត្រូវបានធ្វើឡើងគ្រប់ពេល និងត្រូវផ្តល់ភស្តុតាងច្បាស់លាស់មកកាន់ក្រុមហ៊ុន ទីតាន ស្តូន ឡាយហ្វ៍។
- ង. ក្រុមហ៊ុន ទីតាន ស្តូន ឡាយហ្វ៍ រក្សាសិទ្ធិក្នុងការបដិសេធការទូទាត់អត្ថប្រយោជន៍ធានារ៉ាប់រងប្រសិនបើការទទួលខុសត្រូវលើសំណងនៃអត្ថប្រយោជន៍ធានារ៉ាប់រងនោះ ស្ថិតក្នុងករណីលើកលែងដែលស្រប តាម ខ និងលក្ខខណ្ឌនៃគម្រោងមូលដ្ឋាន ឬ ក្រោមបណ្ណសន្យារ៉ាប់រងនេះ(ប្រសិនបើមាន)។
- ច. គ្រប់ពេលដែលចាំបាច់ ក្រុមហ៊ុន ទីតាន ស្តូន ឡាយហ្វ៍ រក្សាសិទ្ធិក្នុងការតម្រូវឲ្យអ្នកត្រូវបានធានារ៉ាប់រង ទទួលយកការពិនិត្យសុខភាពបែបវេជ្ជសាស្ត្រតាមការរៀបចំដោយវេជ្ជបណ្ឌិតរបស់ក្រុមហ៊ុនដើម្បីកំណត់បានអំពីវិសាលភាពនៃពិការភាព។

១៣.៣ មុនពេលទូទាត់អត្ថប្រយោជន៍ទាំងនេះ ក្រុមហ៊ុន ទីតាន ស្តូន ឡាយហ្វ៍ នឹងកាត់កងបំណុលដែលជំពាក់ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ ស្របតាមបណ្ណសន្យារ៉ាប់រងនេះ (ប្រសិនបើមាន)។

១៣.៤ ទឹកប្រាក់សំណងនៃអត្ថប្រយោជន៍ពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍ នឹងត្រូវបានទូទាត់ជូនទៅអ្នកត្រូវបានធានារ៉ាប់រងតែប៉ុណ្ណោះ។

### ប្រការ១៤ ៖ ការបញ្ឈប់បណ្ណសន្យារ៉ាប់រងដោយម្ចាស់បណ្ណសន្យារ៉ាប់រង

១៤.១ ក្នុងអំឡុងពេលបណ្ណសន្យារ៉ាប់រងកំពុងមានសុពលភាព ម្ចាស់បណ្ណសន្យារ៉ាប់រងមានសិទ្ធិបញ្ឈប់បណ្ណសន្យារ៉ាប់រងតាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុម

ហ៊ុនទីតាន ស្តូន ឡាយហ្វ៍។ ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវចុះហត្ថលេខានៅលើទម្រង់បែបបទស្នើសុំលុបចោលបណ្ណសន្យារ៉ាប់រង ហើយបណ្ណសន្យារ៉ាប់រងនឹងត្រូវបានបញ្ចប់ភ្លាមៗបន្ទាប់ពីការចុះហត្ថលេខានោះ។

១៤.២ នៅពេលបញ្ឈប់បណ្ណសន្យារ៉ាប់រង តម្លៃសាច់ប្រាក់សុទ្ធ នឹងត្រូវបានទូទាត់(ប្រសិនបើមាន)។

### ប្រការ១៥៖ ករណីដែលមិនធានា

**ករណីដែលមិនធានា ក្នុងករណីទទួលមរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍៖**

ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ នឹងមិនទូទាត់អត្ថប្រយោជន៍ធានារ៉ាប់រងនៃបណ្ណសន្យារ៉ាប់រងនេះឡើយប្រសិនបើមរណភាពឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍របស់អ្នកត្រូវបានធានារ៉ាប់រង កើតឡើងដោយសារមូលហេតុណាមួយ ទោះបីដោយផ្ទាល់ ឬដោយប្រយោលក្តី ក្នុងចំណោមហេតុការណ៍ដូចខាងក្រោម៖

ក. អត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឲ្យមានរបួសដល់ខ្លួនឯងដោយចេតនា ដោយមិនគិតអំពីស្ថានភាពផ្លូវចិត្តរបស់អ្នកត្រូវបានធានារ៉ាប់រងឡើយ ឬ

ខ. ការឆ្លងមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺដែលពាក់ព័ន្ធនឹងជំងឺអេដស៍ ឬ

គ. ការប្រើប្រាស់គ្រឿងញៀន ឬសារធាតុញៀនខុសច្បាប់ផ្សេងទៀត ឬ ពិសារហួសកម្រិតនូវជាតិអាល់កុល ឬបើកបរយានយន្តក្រោមឥទ្ធិពលនៃគ្រឿងស្រវឹងដូចដែលបានកំណត់ក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមាន ឬ

ឃ. បទល្មើស ដែលប្រព្រឹត្តដោយម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ។

នៅក្នុងករណីដែលក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ ធ្វើការបដិសេធការទាមទារសំណងដូចបានរៀបរាប់ក្នុងលក្ខខណ្ឌចំនុច ក ខ និងគ ខាងលើ នោះចំនួនទឹកប្រាក់ដែលនឹងត្រូវទូទាត់ត្រូវបានកំណត់ត្រឹម៖

i. តម្លៃបោះបង់បណ្ណសន្យារ៉ាប់រង

ii. ដកមកវិញនូវចំនួនទឹកប្រាក់ដែលនៅជំពាក់ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ (ប្រសិនបើមាន)។

នឹងមិនមានការទូទាត់អ្វីទាំងអស់ប្រសិនបើមានករណីក្នុងលក្ខខណ្ឌចំនុច ឃ។

បណ្ណសន្យារ៉ាប់រងនឹងត្រូវបញ្ចប់ដោយការទូទាត់នេះ។

## ជំពូកទី V ដំណោះស្រាយលើការទាមទារសំណង

### ប្រការ១៦ ៖ អ្នកទទួលបានអត្ថប្រយោជន៍ធានារ៉ាប់រង

អត្ថប្រយោជន៍ធានារ៉ាប់រងទូទៅនឹងត្រូវទូទាត់ជូនអ្នកទទួលបានអត្ថប្រយោជន៍ពេញសិទ្ធិទៅតាមលំដាប់លំដោយអាទិភាពដូចខាងក្រោម ប្រសិនបើមិនមានការតែងតាំងជាក់លាក់ណាមួយដោយម្ចាស់បណ្ណសន្យារ៉ាប់រងក្នុងពាក្យសុំធានារ៉ាប់រង៖

ក. ម្ចាស់បណ្ណសន្យារ៉ាប់រង ឬ

ខ. អ្នកទទួលផល (ក្នុងករណីដែលអ្នកទទួលផលណាម្នាក់ទទួលមរណភាពមុនអ្នកត្រូវបានធានារ៉ាប់រង ចំណែករបស់អ្នកទទួលផលនេះ នឹងត្រូវបែងចែកដោយស្មើៗគ្នាឲ្យទៅអ្នកទទួលផលផ្សេងទៀត) ឬ

គ. ទាយាទស្របច្បាប់របស់អ្នកត្រូវបានធានារ៉ាប់រង។

### ប្រការ១៧ ៖ ការជូនដំណឹង និងការផ្តល់ភស្តុតាងនៃការទាមទារសំណង

១៧.១ នៅពេលហេតុការណ៍ដែលត្រូវបានធានាធានារ៉ាប់រងកើតឡើងអ្នកទទួលបានអត្ថប្រយោជន៍ធានារ៉ាប់រងត្រូវ៖

១៧.១.១ ជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុន ទីតាន ស្តូន ឡាយហ្វ៍ អំពីការទាមទារសំណងនៅក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទហេតុការណ៍។

១៧.១.២ ផ្តល់ជូនក្រុមហ៊ុន ទីតាន ស្តូន ឡាយហ្វ៍ នូវព័ត៌មាន និងភស្តុតាងតម្រូវ ដោយចំណាយផ្ទាល់ខ្លួន ដើម្បីបំពេញតាមលក្ខខណ្ឌនៃការទាមទារសំណង៖

ក. វិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិត

ខ. ពាក្យស្នើសុំទាមទារសំណង

គ. សេចក្តីចម្លងសំបុត្រមរណភាព ឬ សេចក្តីបញ្ជាក់អំពីពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍ចេញដោយមន្ទីរពេទ្យ ឬ អាជ្ញាធរមានសមត្ថកិច្ច

ឃ. ឯកសារថតចម្លងអត្តសញ្ញាណបណ្ណ លិខិតឆ្លងដែន សៀវភៅគ្រួសារ សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ ឬ ឯកសារផ្សេងទៀតរបស់អ្នកទទួលផល ដែលបញ្ជាក់អំពីទំនាក់ទំនងជាមួយអ្នកត្រូវបានធានារ៉ាប់រង

ង. របាយការណ៍ប៉ូលីស

ច. របាយការណ៍វេជ្ជសាស្ត្រ

ឆ. លិខិតយល់ព្រមរបស់អ្នកទទួលផល ឬទាយាទក្នុងការបង្ហាញព័ត៌មានផ្ទាល់ខ្លួន

ជ. លិខិតយល់ព្រមបង្ហាញព័ត៌មានដែលទាក់ទងនឹងប្រវត្តិជំងឺរបស់អ្នកត្រូវបានធានារ៉ាប់រង(ប្រសិនបើមាន)

ឈ. លិខិតបញ្ជាក់ ឬ ឯកសារផ្សេងទៀតដែលមានសារៈសំខាន់ក្នុងការវាយតម្លៃលើការទូទាត់សំណង។ រាល់ការស្នើសុំឯកសារទាំងឡាយ និងការចំណាយផ្សេងទៀត ជាបន្ទុករបស់អ្នកទាមទារសំណង។

១៧.១.៣ បន្ទាប់ពីការអនុម័តយល់ព្រមទូទាត់ការទាមទារសំណង ក្រុមហ៊ុនទីតាន ស្តូន ឡាយហ្វ៍ នឹងធ្វើការទូទាត់អត្ថប្រយោជន៍ធានារ៉ាប់រងដោយផ្អែកតាម ខ និងលក្ខខណ្ឌដែលបានចែងក្នុងប្រការ១៣។

**ប្រការ១៨៖ រយៈពេលកំណត់សម្រាប់ការស្នើសុំទូទាត់អត្ថប្រយោជន៍ធានារ៉ាប់រង**

ក្នុងករណីមរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍របស់អ្នកត្រូវបានធានារ៉ាប់រង រយៈពេលកំណត់សម្រាប់ការស្នើសុំទូទាត់អត្ថប្រយោជន៍ធានារ៉ាប់រង គឺមានរយៈពេល១២(ដប់ពីរ)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលមរណភាព ឬគ្រោះថ្នាក់ដែលបណ្តាលឲ្យពិការភាព។ បន្ទាប់ពីផុតរយៈពេល១២(ដប់ពីរ) ខែមានន័យថាម្ចាស់បណ្ណសន្យារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង ឬ អ្នកទទួលផលបានបោះបង់ចោលសិទ្ធិទាំងអស់របស់ខ្លួនក្នុងការទាមទារសំណងពីអត្ថប្រយោជន៍ ដែលពាក់ព័ន្ធទៅនឹងបណ្ណសន្យារ៉ាប់រងនេះ។

## ជំពូកទី VI បញ្ញត្តិផ្សេងៗ

**ប្រការ១៩៖ ការបញ្ចប់បណ្ណសន្យារ៉ាប់រង**

បណ្ណសន្យារ៉ាប់រងនឹងត្រូវបញ្ចប់ នៅពេលហេតុការណ៍ណាមួយក្នុងចំណោមហេតុការណ៍ខាងក្រោមបានកើតឡើង៖

ក. បណ្ណសន្យារ៉ាប់រងត្រូវបានបញ្ចប់តាមសំណើរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ដូចបានបញ្ជាក់ក្នុងបណ្ណសន្យារ៉ាប់រងនេះ ឬ

ខ. ពេលផុតកំណត់នៃបណ្ណសន្យារ៉ាប់រង ឬ

គ. អត្ថប្រយោជន៍នៅពេលមរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍ត្រូវបានទូទាត់រួចរាល់

ឃ. បណ្ណសន្យារ៉ាប់រងមិនត្រូវបានបន្តសុពលភាពឡើងវិញក្នុងរយៈពេល២៤ (ម្ភៃបួន)ខែ បន្ទាប់ពីអស់សុពលភាព ឬ

ង. ករណីផ្សេងទៀត ដែលបានកំណត់នៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២០៖ ការរក្សាការសម្ងាត់ព័ត៌មាន**

រាល់ព័ត៌មានដែលបានផ្តល់ជូនក្រុមហ៊ុន ទីតាន ស្តូន ឡាយហ្វ៍ នឹងត្រូវរក្សាជាព័ត៌មានសម្ងាត់ ហើយក្រៅពីទីតាន ស្តូន គ្រុប គ្មានព័ត៌មានផ្ទាល់ខ្លួនណាមួយនឹងត្រូវបញ្ចេញទៅឲ្យភាគីទីបីដោយគ្មានការយល់ព្រមជាមុនឡើយលើកលែងតែបានតម្រូវ ឬអនុញ្ញាតឲ្យធ្វើបែបនេះដោយច្បាប់ ឬបទប្បញ្ញត្តិជាធរមាន។

**ប្រការ២១៖ ការផ្សះផ្សាវិវាទ**

ចំពោះគ្រប់វិវាទ ដែលពាក់ព័ន្ធនឹងអាជីវកម្មធានារ៉ាប់រង ភាគីណាមួយនៃភាគីវិវាទអាចនាំយកវិវាទទៅជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីសម្រុះសម្រួលធ្វើការផ្សះផ្សាវិវាទមុននឹងប្តឹងទៅវេទិកាមជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ច លើកលែងតែរឿងព្រហ្មទណ្ឌ។

**ប្រការ២២៖ ច្បាប់គ្រប់គ្រង**

ឯកសារនេះត្រូវបានគ្រប់គ្រង និងបកស្រាយដោយស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

# Policy Provision
# On Lovely Family

## Table of Content


| | |
|---|---|
| **Chapter 1:** | **General Provision** |
| Article 1: | Definition |
| Article 2: | Insurance Purchasing Procedure |
| Article 3: | Disclosure obligation by the Policy Owner |
| Article 4: | Temporary Insurance Coverage |
| Article 5: | Free-look Period |
| Article 6: | Point of Time When Insurance Liability Arises |
| **Chapter 2:** | **Payment of Premiums** |
| Article 7: | Premium Payment Obligation |
